ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ : ១៣៥/១៧ ល.ក

# របាយការណ៍

## ស្តីពីការចុះសិក្សាអំពីស្ថានភាពនៃការបញ្ជូនពលករត្រឡប់មកពីប្រទេសថៃ និងការស្វែងរកដំណោះស្រាយសមស្របសម្រាប់ពលករឆ្លងកាត់ព្រំដែន ក្រោមការសម្របសម្រួលពីអាជ្ញាធរ និងសមត្ថកិច្ចខេត្តជាប់ព្រំដែន

## ខេត្តប៉ៃលិន បាត់ដំបង និងខេត្តបន្ទាយមានជ័យ
## ថ្ងៃទី ១៥-១៧ ខែកក្កដា ឆ្នាំ២០១៧

បន្ទាប់ពីអាជ្ញាធរថៃអនុវត្តច្បាប់អន្តោប្រវេសន៍ ៨ចំណុចក្នុងការគ្រប់គ្រងពលករបរទេស ដោយបានចាប់ពលករខ្មែរខុសច្បាប់បញ្ជូនត្រឡប់មកកម្ពុជាវិញរាប់ពាន់នាក់ នៅច្រកទ្វារអន្តរជាតិប៉ោយប៉ែត ។ ជាក់ស្តែង នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧នេះ ឃើញសមត្ថកិច្ចថៃបានចាប់ពលករខ្មែរធ្វើការងារដោយខុសច្បាប់បញ្ជូនត្រឡប់មកកម្ពុជាវិញចំនួនជាង៥.០០០នាក់ ច្រើនជាងសព្វដងដែលមានប្រមាណតែ ១៥០ទៅ២០០នាក់ក្នុងមួយថ្ងៃ ។ ពលករខ្មែរដែលថៃចាប់បញ្ជូនមក គឺជាពលករស្នាក់នៅធ្វើការងារដោយខុសច្បាប់ គ្មានឯកសារគ្រប់គ្រាន់ដូចជាលិខិតឆ្លងដែន និងប័ណ្ណការងារជាដើម ។ ក្នុងរយៈពេល ៦ខែដើមឆ្នាំ២០១៧នេះ ថៃបានបញ្ជូនពលករខ្មែរខុសច្បាប់ត្រឡប់មកកម្ពុជាវិញចំនួនជាង៨៩.០០០នាក់ ដែលចំនួននេះប្រហាក់ប្រហែលនឹងការបញ្ជូនត្រឡប់ក្នុងរយៈពេលមួយឆ្នាំ២០១៦ ។

ពាក់ព័ន្ធនឹងបញ្ហាដែលត្រូវការវិធានការដោះស្រាយ និងគ្រប់គ្រងជាបន្ទាន់នេះ និងដោយទទួលបានអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ** នៅក្នុងកិច្ចប្រជុំអន្តរក្រសួង ស្តីពីលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ប្រចាំឆមាសទី១ ឆ្នាំ២០១៧ កាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧ **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ** បានដឹកនាំគណៈប្រតិភូក្រុមការងារអន្តរក្រសួង ចុះបំពេញបេសកកម្មការងារចំនួន០៣ថ្ងៃ (ពីថ្ងៃទី១៥-១៧ ខែកក្កដា ឆ្នាំ២០១៧) ទៅកាន់ខេត្តជាប់ព្រំដែនប្រទេសថៃចំនួន០៣គឺ ខេត្តប៉ៃលិន បាត់ដំបង និងខេត្តបន្ទាយមានជ័យ ដើម្បីសិក្សាអំពីស្ថានភាពនៃការបញ្ជូនពលករត្រឡប់មកពីប្រទេសថៃ និងការស្វែងរកដំណោះស្រាយសមស្របសម្រាប់ពលករឆ្លងកាត់ព្រំដែន ក្រោមការសម្របសម្រួលពីអាជ្ញាធរ និងសមត្ថកិច្ចខេត្តជាប់ព្រំដែន ។

បេសកកម្មការងារនេះបានប្រព្រឹត្តទៅដោយមានកិច្ចសហការល្អពីអាជ្ញាធរមូលដ្ឋាន សមត្ថកិច្ច និងមន្ត្រីតំណាងមកពីមន្ទីរ-អង្គភាពជំនាញពាក់ព័ន្ធ ហើយទទួលបានលទ្ធផលគួរឲ្យកត់សម្គាល់ ដូចខាងក្រោម៖

### ក. សមាសភាពគណៈប្រតិភូ

សមាសភាពគណៈប្រតិភូមានចំនួន ១០នាក់ (ស្រី ៥នាក់)៖

| | | | |
|---|---|---|---|
| ១. លោកជំទាវ | ជូ ប៊ុនអេង | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ | |
| ២. លោកជំទាវ | សាន្ត អរុណ | រដ្ឋលេខាធិការ | ក្រសួងកិច្ចការនារី |
| ៣. ឯកឧត្តម ឧ.ឯក | ចៅង សំអាត | អគ្គលេខាធិការ | គ.ជ.ប.ជ |

| | | | |
|---|---|---|---|
| ៤. ឯកឧត្តម ឧ.ឯក | យ៉ែម ច័ន្ទណារុំ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ៥. លោកជំទាវ ឧ.ឯក | ប៉ុណ្ណ សំខាន់ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ៦. លោកជំទាវ | រ៉ែន សិរីលក្ខិណា | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ៧. លោកស្រី | ព្រុំ សុខន | ប្រធាននាយកដ្ឋាន | ក្រសួងសង្គមកិច្ច |
| ៨. លោក | ឆេង វណ្ណា | អនុប្រធានលេខាធិការដ្ឋាន | គ.ជ.ប.ជ |
| ៩. លោក វ.ទោ | អ៊ុំ ជារ៉ែន | នាយការិយាល័យ | គ.ជ.ប.ជ |
| ១០. លោក វ.ត្រី | ហ៊ី រតនៈ | នាយរងការិយាល័យ | គ.ជ.ប.ជ |

## ខ. សកម្មភាពការងារ

### ❖ នៅខេត្តប៉ៃលិន

- ជួបប្រជុំពិភាក្សាជាមួយអភិបាលខេត្តប៉ៃលិន រួមនឹងអាជ្ញាធរមូលដ្ឋាន សមត្ថកិច្ច និងតំណាងមន្ទីរ-អង្គភាពជំនាញពាក់ព័ន្ធ នៅសាលាខេត្តប៉ៃលិន មានសមាសភាពចូលរួមចំនួន ២១នាក់ (ស្រី ១៣នាក់) ។
- ចុះពិនិត្យច្រកទ្វារអន្តរជាតិព្រំ និងច្រកផ្លូវដើរចំនួន ០២ នៅចំណុចបង្គោលព្រំដែនលេខ ៦៣ និងលេខ ៦៥ ។
- សម្ភាសន៍ និងណែនាំពលករខ្មែរឆ្លងកាត់ព្រំដែនចូលមកកម្ពុជាវិញចំនួន ០៩នាក់ (ស្រី ០៣នាក់) ។
- សាកសួរ និងណែនាំក្រុមហ៊ុនទេសចរណ៍ និងដឹកជញ្ជូនពលករ (SK) ។
- ជូនអំណោយដល់សមត្ថកិច្ចព្រំដែន និងពលករដែលបានសម្ភាសន៍ ។

### ❖ នៅខេត្តបាត់ដំបង

- ជួបប្រជុំពិភាក្សាជាមួយអភិបាលខេត្តបាត់ដំបង រួមនឹងអាជ្ញាធរមូលដ្ឋាន សមត្ថកិច្ច និងតំណាងមន្ទីរ-អង្គភាពជំនាញពាក់ព័ន្ធ នៅសាលាខេត្តបាត់ដំបង មានសមាសភាពចូលរួមចំនួន ២២នាក់ (ស្រី ១០នាក់) ។
- ចុះពិនិត្យច្រកទ្វារអន្តរជាតិដូង និងច្រកផ្លូវដើរចំនួន ០១ ឈ្មោះច្រកច័ន្ទគីរី នៅក្បែរច្រកទ្វារអន្តរជាតិដូង គ្រប់គ្រងដោយនគរបាលរ:ការពារព្រំដែនលេខ ៨១៩ ។
- សម្ភាសន៍ និងណែនាំពលករខ្មែរឆ្លងកាត់ព្រំដែនជាច្រើននាក់ និងបានជួបពិភាក្សាផ្លាស់ប្តូរយោបល់ជាមួយសមត្ថកិច្ចថៃ ។
- ជូនអំណោយដល់សមត្ថកិច្ចព្រំដែន និងពលករដែលបានសម្ភាសន៍ ។
- ចុះពិនិត្យមើលទីតាំងដីសម្រាប់កសាងមណ្ឌលសំចត ។

### ❖ នៅខេត្តបន្ទាយមានជ័យ

- ជួបប្រជុំពិភាក្សាជាមួយ អភិបាលខេត្តបន្ទាយមានជ័យ រួមនឹងអាជ្ញាធរមូលដ្ឋាន សមត្ថកិច្ច និងតំណាងមន្ទីរ-អង្គភាពជំនាញពាក់ព័ន្ធ នៅសាលាខេត្តបន្ទាយមានជ័យ មានសមាសភាពចូលរួមចំនួន ៤៣នាក់ (ស្រី ១១នាក់) ។
- ចុះពិនិត្យច្រកទ្វារអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារតំបន់ស្រុកម៉ាឡៃ គ្រប់គ្រងដោយនគរបាលវរ:ព្រំដែនលេខ ៨១៥ ។
- សម្ភាសន៍ ណែនាំ និងជូនអំណោយដល់ពលករដែលថៃចាប់បញ្ជូនមក នៅមជ្ឈមណ្ឌលផ្តល់ជំនួយផ្នែកចំណាកស្រុក ក្រុងប៉ោយប៉ែត ។
- ចុះពិនិត្យមើលទីតាំងដីសម្រាប់កសាងមណ្ឌលសំចតនៅក្នុងក្រុងប៉ោយប៉ែត ។

## គ. លទ្ធផលទទួលបាន

### ១. ស្ថានភាពតាមបណ្ដាច្រកទ្វារព្រំដែន

#### ❖ ស្ថានភាពតាមបណ្ដាច្រកទ្វារព្រំដែនខេត្តប៉ៃលិន

នៅច្រកទ្វារអន្តរជាតិព្រំ មិនមានការចាប់បញ្ជូនពលករមកទេ មានតែពលករដែលឆ្លងដែនស្របច្បាប់ចេញចូលទៅធ្វើការងារជាធម្មតា ។ ពលករដែលឆ្លងកាត់តាមច្រកនេះ ច្រើនជាពលករដែលមានលទ្ធភាព បានត្រៀមខ្លួន និងមានឯកសារស្របច្បាប់ ហើយពេលពួកគាត់ចូលមកកម្ពុជាវិញមានឥរិយាបថរីករាយ និងមានបំណងត្រឡប់ទៅធ្វើការនៅថៃវិញ ពួកគាត់ចូលមកវិញដើម្បីធ្វើបែបបទ ។ ពលករដែលចូលមកតាមច្រកនេះ ច្រើនធ្វើដំណើរតាមរថយន្តក្រុងមកដល់ព្រំដែន រួចបន្តដំណើរតាមរយៈរថយន្តក្រុមហ៊ុនទេសចរនិងដឹកជញ្ជូនពលករមួយឈ្មោះ SK (Savuth Khemra) នៅខេត្តប៉ៃលិនមិនមានក្រុមហ៊ុនជ្រើសរើសពលករទេ មានតែក្រុមហ៊ុនដឹកជញ្ជូននេះមួយគត់ ។ ពលករដែលចូលមកកម្ពុជាវិញត្រូវបាននគរបាលអន្តោប្រវេសន៍ធ្វើការពិនិត្យ សាកសួរ និងធ្វើបែបបទចេញចូល ទោះធ្វើដំណើរជាលក្ខណៈឯកជន ឬតាមក្រុមហ៊ុនក៏ដោយ ដើម្បីធ្វើការស្រង់ទិន្នន័យឲ្យបានច្បាស់លាស់ និងរាយការណ៍ជាប្រចាំថ្ងៃ ។ ក្នុងរយៈពេលកន្លះខែនេះ ប្រជាពលរដ្ឋចូលមកតាមច្រកទ្វារអន្តរជាតិព្រំនេះចំនួន ៧៥៨នាក់ (ស្រី ៣៤២នាក់) ។

កាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៧ បានសម្ភាសន៍ពលករដែលចេញតាមច្រកទ្វារអន្តរជាតិព្រំចំនួន ១២នាក់ ក្នុងនោះមានតែ ២នាក់ទេដែលមានលិខិតឆ្លងដែន និង ១០នាក់ទៀតមានប័ណ្ណស៊ីជម្ពូ ហើយពួកគាត់ចេញមកនេះដើម្បីធ្វើបែបបទ (ពេលចេញទៅ ចេញតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត) ។ មូលហេតុដែលពួកគាត់ចេញមកតាមច្រកទ្វារអន្តរជាតិព្រំនេះដោយសារងាយស្រួលប្រថាប់ត្រា និងមិនរង់ចាំយូរដូចនៅច្រកអន្តរជាតិប៉ោយប៉ែត ។

នៅច្រកផ្លូវដើរចំណុចបង្គោលព្រំដែនលេខ ៦៣ ក្បែរច្រកទ្វារអន្តរជាតិព្រំ ត្រូវបានបិទមិនអនុញ្ញាតិឲ្យចេញចូលតាំងពីថ្ងៃរាជរដ្ឋាភិបាលប្រកាសឲ្យបិទ ហើយខាងថៃក៏មានធ្វើរបងបិទផងដែរ ។

នៅច្រកផ្លូវដើរចំណុចបង្គោលព្រំដែនលេខ ៦៥ ពីមុនមានសកម្មភាពចេញចូលច្រើន តែបន្ទាប់ពីថ្ងៃរាជរដ្ឋាភិបាលប្រកាសឲ្យបិទមក ហាក់មានសភាពស្ងប់ស្ងាត់បន្តិចតែនៅតែមានចេញចូលខ្លះៗ ព្រោះមិនមានរបងឬលួសការពារ ។ ច្រកដែលច្រើនមានបញ្ហាគឺច្រកចំណុចបង្គោលព្រំដែនលេខ ៦៥ ៦៦ និង៦៧ ។

#### ❖ ស្ថានភាពតាមបណ្ដាច្រកទ្វារព្រំដែនខេត្តបាត់ដំបង

នៅច្រកទ្វារអន្តរជាតិដូង មិនមានពលករចេញទៅដោយខុសច្បាប់ទេ មានតែពលករដែលត្រូវអាជ្ញាធរថៃចាប់បញ្ជូនមក ហើយការបង្វែរការបញ្ជូនពលករមកតាមច្រកទ្វារអន្តរជាតិដូងនេះ គឺដោយសារទីតាំងភូមិសាស្ត្រធំទូលាយងាយស្រួលក្នុងការបញ្ជូន និងត្រួតពិនិត្យ ។ ពេលបញ្ជូនពលករគឺខាងថៃបានឲ្យបញ្ជីឈ្មោះមក ហើយនគរបាលអន្តោប្រវេសន៍កម្ពុជាជាអ្នកពិនិត្យ រាប់ចំនួន សាកសួរ ណែនាំ និងផ្តល់អាហារ ដោយខាងកម្ពុជាយើងបានធ្វើរោងតង់សម្រាប់ទទួល ។ អាជ្ញាធរខេត្តបាត់ដំបងបានចុះទៅពិនិត្យ និងសិក្សា ដោយសង្កេតឃើញថាស្ថានភាពនៃការបញ្ជូនមកមិនលំបាកដូចការបញ្ជូនមកយ៉ាងគំហុកកាលពីឆ្នាំ២០១៤នោះទេ ការបញ្ជូនមកមានចំនួនតិច ហើយប្រជាពលរដ្ឋមានការយល់ដឹងច្រើនជាងមុន ។ ក្នុងសប្តាហ៍ទី១ ខែកក្កដា ពលករបញ្ជូនមកមានចំនួន ១.៦៤៣នាក់ និងសប្តាហ៍ទី២ ថយចុះមកនៅចំនួន ១៩២នាក់ តាំងពីថ្ងៃទី១២ ខែកក្កដាមក ការបញ្ជូនពលករហាក់មានសភាពស្ងប់ស្ងាត់ ។

នៅច្រកចន្ទគីរី ក្បែរច្រកទ្វារអន្តរជាតិដូង គ្រប់គ្រងដោយនគរបាលវរៈការពារព្រំដែនលេខ ៨១៩ ត្រូវបានបិទមិនឲ្យចេញចូលប្រហែល ៤ខែមកហើយ ហើយខាងថៃបានដាក់ខ្សែលួសការពារទៀតផង ។

ពាក់ព័ន្ធនឹងការចាប់បញ្ជូនពលករមក ឯកឧត្តមអភិបាលខេត្តបាត់ដំបង បានដឹកនាំគណៈប្រតិភូខេត្តទៅជួបប្រជុំពិភាក្សាជាមួយអាជ្ញាធរខេត្តជាប់ព្រំដែន ដើម្បីធ្វើការសម្របសម្រួល និងដោះស្រាយបញ្ហាប្រឈម ជាលទ្ធផលអាជ្ញាធរថៃបានកោតសសើរអាជ្ញាធរខេត្តបាត់ដំបង ដែលបានយកចិត្តទុកដាក់ក្នុងការសហការគ្នាបានទាន់សភាពការណ៍ ហើយអាជ្ញាធរ និងសមត្ថកិច្ចថៃបានជួយសម្របសម្រួលពលករខ្មែរឲ្យចេញមកដើម្បីធ្វើលិខិតឆ្លងដែន និងឯកសារស្របច្បាប់ផ្សេងៗ និងជួយសម្រួលដល់ប្រជាពលរដ្ឋដែលនៅតាមខ្សែបន្ទាត់ព្រំដែនឆ្លងទៅធ្វើការព្រឹកវិលល្ងាច ។

❖ **ស្ថានភាពតាមបណ្តាច្រកទ្វារព្រំដែនខេត្តបន្ទាយមានជ័យ**

នៅតាមបណ្តាយខ្សែបន្ទាត់ព្រំដែនខេត្តបន្ទាយមានជ័យ ភាគច្រើនពលករចេញដោយខុសច្បាប់ទៅតាមច្រករបៀង ហើយបន្ទាប់ពីអាជ្ញាធរថៃអនុវត្តវិធានការគ្រប់គ្រងពលករបរទេស ពលករខ្មែរភាគច្រើនត្រូវបានចាប់បញ្ជូនមកតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត និងមួយចំនួនរត់ចេញតាមច្រករបៀង ។

នៅច្រកទ្វារអន្តរជាតិប៉ោយប៉ែត កាលពីចុងខែមិថុនា ការចាប់បញ្ជូនពលករមកមានចំនួនច្រើនរាប់ពាន់នាក់ក្នុង១ថ្ងៃ ដែលថ្ងៃខ្លះមានជាង៥ពាន់នាក់ តែនៅដើមខែកក្កដានេះមានការថយចុះជាបន្តបន្ទាប់មកនៅត្រឹម ៦០០ទៅ៩០០នាក់ ហើយនៅថ្ងៃទី១៧ ខែកក្កដា ធ្លាក់មកនៅត្រឹម១៧៤នាក់ (ចំនួនធ្លាក់មកនៅត្រឹមក្រោមឬលើស១០០នាក់ក្នុង១ថ្ងៃ) ។ ការដឹកជញ្ជូនមកគឺតាមរយៈឡានទ្រុង ដែលផ្ទុកជាមធ្យម ៥០នាក់ក្នុង១ឡាន ។ ពេលដឹកជញ្ជូនមក នគរបាលអន្តោប្រវេសន៍ជាអ្នកពិនិត្យ និងរាប់ចំនួនដើម្បីរាយការណ៍ប្រចាំថ្ងៃ បន្ទាប់មកបញ្ជូនមកដាក់នៅមជ្ឈមណ្ឌលផ្តល់ជំនួយផ្នែកចំណាកស្រុក ក្រុងប៉ោយប៉ែត ដែលមានអង្គការចំនួន០៣ធ្វើការរួមគ្នាមាន IOM, Samaritan's purse និងដំណក់ទឹក ដើម្បីធ្វើការសម្ភាសន៍ ណែនាំ ផ្តល់អាហារ និងដឹកជញ្ជូនទៅកាន់លំនៅដ្ឋាន ។

នៅច្រកទ្វារតំបន់ស្រុកម៉ាឡៃ គ្រប់គ្រងដោយនគរបាលវរៈព្រំដែនលេខ ៨១៥ មិនមានការចាប់បញ្ជូនពលករមកទេ ជាទូទៅមានតែប្រជាពលរដ្ឋនៅតាមភូមិ-ឃុំជាប់ព្រំដែនចេញចូលទៅស៊ីឈ្នួលស្ទូងស្រូវជិតៗ ទៅព្រឹកវិលល្ងាច ដោយទទួលបានកម្រៃ៣០០បាតក្នុងមួយថ្ងៃ ហើយពួកគាត់ចេញទៅតាមរយៈមេភូមិទាំងសងខាងទំនាក់ទំនងគ្នា ដែលចេញទៅជាមធ្យម២០០នាក់ក្នុង១ថ្ងៃ តែចាប់តាំងពីថ្ងៃរាជរដ្ឋាភិបាលប្រកាសឲ្យបិទច្រកមក ប្រជាពលរដ្ឋទាំងនោះមិនត្រូវបានអនុញ្ញាតឲ្យចេញទៅទៀតទេ ដែលធ្វើឲ្យពួកគាត់បាត់បង់ចំណូលប្រចាំថ្ងៃផងដែរ ។ ស្រុកម៉ាឡៃមានឃុំចំនួន០៦ ក្នុងនោះមាន០៥ឃុំជាប់ព្រំដែន ដែលមាន០៨ប៉ុស្តិ៍ច្រកទ្វារ ហើយនគរបាលអាចក្តាប់ប្រជាពលរដ្ឋក្នុងមូលដ្ឋានបានច្បាស់ ។ នគរបាលវរៈព្រំដែនប្រចាំនៅច្រកទ្វារនេះបានលើកឡើងនូវវិធានការក្នុងការគ្រប់គ្រប់ប្រជាពលរដ្ឋទៅធ្វើការប្រចាំថ្ងៃនេះគឺ ឲ្យមេភូមិស្រង់ស្ថិតិ និងធ្វើបញ្ជីឈ្មោះប្រជាពលរដ្ឋដែលត្រូវចេញទៅធ្វើការ ហើយពេលពួកគាត់ចេញទៅត្រូវប្រគល់បញ្ជីឈ្មោះឲ្យនគរបាលច្រកទ្វារ ដើម្បីធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ចំនួនពេលចេញទៅ និងពេលចូលមកវិញឲ្យបានច្បាស់លាស់ ។

## ២. បញ្ហាប្រឈម

- ការចាប់បញ្ជូនពលករមកច្រើនបែបនេះ ធ្វើបានឲ្យនិយោជកថៃមានបញ្ហាលំបាកស្ទះសង្វាក់ផលិតកម្ម ហើយពលករខ្មែរក៏បាត់បង់ចំណូលផងដែរ ។
- ចំពោះការបិទច្រករបៀងបានបង្កផលលំបាកដល់ប្រជាពលរដ្ឋដែលឆ្លងដែនទៅធ្វើការប្រចាំថ្ងៃ (ទៅព្រឹកវិលល្ងាច) តែបើបើកនោះក៏មានផលអវិជ្ជមានដែរដូចជាការឆ្លងដែនខុសច្បាប់ រត់ពន្ធមនុស្ស និងទំនិញជាដើម ។

- ការធ្វើឯកសាររបស់ពលករដូចជា ប័ណ្ណព្រំដែនជាដើម បើមានមេខ្យល់ ឬអ្នករត់ការធ្វើឲ្យ នោះវានឹងមានតម្លៃកាន់តែថ្លៃ ហើយនឹងធ្វើឲ្យថៅកែថៃអស់ទំនុកចិត្តមកលើអាជ្ញាធរកម្ពុជា ។
- ប័ណ្ណចេញចូលប្រចាំថ្ងៃរបស់ថៃគឺចូលបានត្រឹមផ្សារនៅព្រំដែនតែប៉ុណ្ណោះ តែប្រជាពលរដ្ឋខ្មែរមួយចំនួនបានទៅហួសដោយចេតនាដើម្បីរកការងារ ដែលនាំឲ្យក្លាយជាពលករខុសច្បាប់ ។
- ពលករមួយចំនួនពេលចេញទៅគឺទៅដោយស្របច្បាប់មានលិខិតឆ្លងដែន ឬប័ណ្ណព្រំដែន តែបានលាក់ ឬហែកចោល ដើម្បីឲ្យសមត្ថកិច្ចថៃចាប់បញ្ជូនមក ដោយមិនមានការចំណាយសោហ៊ុយធ្វើដំណើរ ។
- ពេលខ្លះពលករមកដល់ព្រំដែនហួសម៉ោង ៥ល្ងាចដែលគេបិទទ្វារព្រំដែន ដូចនេះដើម្បីចូលមកបាន ត្រូវបង់លុយឲ្យគេ ។
- នឹងមានការផ្លាស់ប្តូរទីតាំងមជ្ឈមណ្ឌលផ្តល់ជំនួយផ្នែកចំណាកស្រុកចេញពីផ្សារមង្គល ដែលនឹងអាចនាំឲ្យការចំណាយក្នុងការដឹកជញ្ជូនកើនឡើង ព្រោះតាមរយៈកិច្ចព្រមព្រៀង ថៃដឹកមកទម្លាក់នៅត្រឹមដើមពោធិ៍ចន្លោះច្រកទ្វារនៃប្រទេសទាំងពីរ ហើយបច្ចុប្បន្ននគរបាលអន្តោប្រវេសន៍បានសម្រួលឲ្យដឹកមកដល់មជ្ឈមណ្ឌលផ្តល់ជំនួយផ្នែកចំណាកស្រុក ដោយចំណាយ២០០បាតក្នុងឡាន ដូចនេះបើប្តូរទីតាំងកាន់តែឆ្ងាយការចំណាយក៏កាន់តែច្រើន ។

## ៣. កិច្ចសម្ភាសន៍ពលករ

### ❖ នៅច្រកទ្វារអន្តរជាតិព្រំ ខេត្តប៉ៃលិន

បានសម្ភាសន៍ពលករ-ពលការីនីចូលមកតាមច្រកទ្វារអន្តរជាតិព្រំ ចំនួន ០៩នាក់ (ស្រី ០៣នាក់) ហើយទទួលបានលទ្ធផលដូចខាងក្រោម៖

- ពួកគាត់មិនបានស្គាល់គ្នាទេ មកជាមួយគ្នានេះគឺដោយសារឡើងជិះរថយន្តក្រុងតាមជើងតែមួយ ហើយស្ថានភាពពួកគាត់មិនមានការព្រួយបារម្ភទេ មានតែញញឹមសប្បាយ និងមានបំណងត្រឡប់ទៅវិញ ។
- ពួកគាត់ធ្វើការនៅបាងកក ជាជាងនៅតាមសិប្បកម្ម និងហាងផ្សេងៗ (មានអ្នកធ្វើការបានពី២ខែរហូតដល់១ឆ្នាំ) ស្នាក់នៅបន្ទប់ជួលរួមគ្នាប្រហែល៥ទៅ៦នាក់ តម្លៃ ៤.០០០បាតក្នុង១ខែ ហើយនៅទីនោះមិនមានការធ្វើបាបពលករទេ ។
- ពួកគាត់ខ្លះចេញទៅថៃតាមរយៈបងប្អូន មិត្តភ័ក្តិ និងខ្លះតាមរយៈមេខ្យល់ ហើយមូលហេតុដែលគាត់ទៅធ្វើការនៅប្រទេសថៃ ព្រោះប្រាក់ខែខ្ពស់ ១០.០០០បាតក្នុង១ខែ (ពួកគាត់ថាធ្វើស្រែ១ឆ្នាំមិនបានដល់ធ្វើការនៅថៃ១ខែផង) ។
- ពួកគាត់ត្រឡប់មកកម្ពុជាវិញដោយសារថៃអនុវត្តវិធានការ ដូចនេះថៅកែបានឲ្យពួកគាត់មកវិញសិន ហើយថៅកែជាអ្នករត់ការធ្វើបែបបទឲ្យ (ក្នុងចំណោម២នាក់ថៅកែចេញលុយឲ្យ១នាក់ហើយ១នាក់ត្រូវធ្វើអស់ ១៨.០០០បាត) ពេលធ្វើរួចថៅកែនឹងហៅត្រឡប់ទៅវិញ ។ ប័ណ្ណស៊ីជម្ពូពីមុនសុពលភាព ១ឆ្នាំតម្លៃ ៣.៥០០បាត តែឥឡូវសុពលភាព២ឆ្នាំតម្លៃ ៥.៨៦០បាត ។
- ពួកគាត់ចេញមកតាមច្រកទ្វារអន្តរជាតិព្រំ ដោយសារមិនមានបង់ប្រាក់ បើចេញតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតត្រូវបង់ប្រាក់ឲ្យគេ ៥០០បាត (តម្លៃរថយន្តបាងកក-ព្រំ ៣៦០បាត និងបាងកក-ប៉ោយប៉ែត ២៣០បាត) ។

❖ **នៅច្រកទ្វារអន្តរជាតិដូង ខេត្តបាត់ដំបង**

បានសម្ភាសន៍ពលករ-ពលការិនីមួយចំនួន ដែលកំពុងចេញចូលឆ្លងកាត់ផ្សារឡែម និងកំពុងស្នាក់នៅជាប់ខ្សែបន្ទាត់ព្រំដែន ហើយទទួលបានលទ្ធផលដូចខាងក្រោម៖

- បានសម្ភាសន៍ស្ត្រីខ្មែរម្នាក់ដែលបានឆ្លងដែនចូលផ្សារឡែមដោយគ្មានលិខិតស្នាមអ្វីទាំងអស់ ហើយមិនចេះភាសាថៃទៀត៖ គាត់ថាគាត់មកពីខេត្តតាកែវ ត្រូវប្តីវាយធ្វើបាប ហើយរត់មកទីនេះដើម្បីរកការងារធ្វើ គាត់ឃើញគេឆ្លងដែនក៏ឆ្លងតាមគេមក ដោយធ្វើប័ណ្ណចេញចូលប្រចាំថ្ងៃរបស់ថៃ ដែលចូលបានត្រឹមផ្សារឡែមប៉ុណ្ណោះ ។ បន្ទាប់មកក្រុមគណៈប្រតិភូយើងបានធ្វើការពន្យល់ណែនាំ ហើយជាចុងក្រោយគាត់បានយល់ព្រមឲ្យអាជ្ញាធរ និងមន្ត្រីជំនាញខេត្តបាត់ដំបង រកការងារឲ្យធ្វើនៅក្នុងប្រទេសកម្ពុជាវិញ ។
- បានសម្ភាសន៍ពលករ ០៤នាក់ (ស្រី ០១នាក់)៖ ពួកគាត់កំពុងមានបញ្ហាមិនអាចចេញទៅកម្ពុជាវិញបាន ដោយសារប័ណ្ណព្រំដែនពួកគាត់មិនបានបោះត្រាចេញរបស់ថៅកែ ពួកគាត់ចេញមកនេះគឺដោយសារចង់ប្តូរថៅកែ បន្ទាប់មកនគរបាលអន្តោប្រវេសន៍កម្ពុជាបានជួយសម្រួលពួកគាត់ចេញមកកម្ពុជាវិញ និងបានណែនាំពួកគាត់ឲ្យធ្វើឯកសារស្របច្បាប់ ។
- បានសម្ភាសន៍ពលករដែលរស់នៅជាប់នឹងខ្សែបន្ទាត់ព្រំដែន ០១គ្រួសារ៖ ពួកគាត់ទៅបេះផ្លែឈើនៅក្នុងទឹកដីថៃ ចូលទៅដោយធ្វើប័ណ្ណចេញចូលសប្តាហ៍តម្លៃ ៧៥.០០០រៀលគ្មានអត្តសញ្ញាណប័ណ្ណ បើមានអត្តសញ្ញាណប័ណ្ណតម្លៃត្រឹមតែ ៣០.០០០រៀលទេ ហើយពួកគាត់អាចទទួលកម្រៃ ៥០០បាតក្នុង១ថ្ងៃ ។

❖ **នៅច្រកទ្វារអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ**

បានសម្ភាសន៍ពលករ-ពលការិនីមួយចំនួននៅមជ្ឈមណ្ឌលផ្តល់ជំនួយផ្នែកចំណាកស្រុក ហើយទទួលបានលទ្ធផលដូចខាងក្រោម៖

- បានសម្ភាសន៍ពលករ-ពលការិនីចំនួន ១៣នាក់(ស្រី ០៧នាក់) ដែលបានចាប់បញ្ជូនមកតាមឡានទ្រុងមកដាក់នៅមជ្ឈមណ្ឌលផ្តល់ជំនួយផ្នែកចំណាកស្រុក៖ ពួកគាត់ទាំង១៣នាក់មិនមានលិខិតឆ្លងដែនទេ ៣នាក់មានប័ណ្ណស៊ីជម្ពូតែហួសសុពលភាព ។ ស្ថានភាពរបស់ពួកគាត់ហាក់មិនភ័យតក់ស្លុតអ្វីទេ ភាគច្រើននៃពួកគាត់ថានឹងធ្វើលិខិតឆ្លងដែន និងបែបបទស្របច្បាប់ដើម្បីត្រឡប់ទៅធ្វើការនៅថៃវិញ ។
- បានសម្ភាសន៍ពលករម្នាក់ឈ្មោះ សន ផាន់ណា ស្រុកកំណើតនៅខេត្តសៀមរាប៖ គាត់ទៅធ្វើការនៅរោងចក្រតាមរយៈក្រុមហ៊ុន ដោយក្រុមហ៊ុនជាអ្នកកាន់កាប់លិខិតឆ្លងដែនរបស់គាត់ ហើយគាត់ចេញមកវិញនេះដោយសារគាត់មានជម្ងឺ តែក្រុមហ៊ុនមិនឲ្យលិខិតឆ្លងដែនគាត់មកទេ គាត់ក៏មកតាមរយៈមេខ្យល់ក្នុងតម្លៃ១.៦០០បាត តែពេលមកដល់ព្រំដែនចាំយូរពេក មេខ្យល់ថាបើចង់ចេញបន្ទាន់ត្រូវបង់៧០០បាតទៀត តែគាត់គ្មានប្រាក់ក៏ទំនាក់ទំនងអង្គការនៅទីឲ្យជួយអន្តរាគមន៍ចេញមក ។

បន្ទាប់ពីកិច្ចសម្ភាសន៍រួចមក ក្រុមគណៈប្រតិភូយើងបានចែកអំណោយជូនពួកគាត់ ហើយមជ្ឈមណ្ឌលផ្តល់ជំនួយផ្នែកចំណាកស្រុកបានចាត់ចែងមធ្យោបាយធ្វើដំណើរជូនពួកគាត់ទៅកាន់លំនៅដ្ឋានរៀងៗខ្លួន ។

**ឃ. អនុសាសន៍ណែនាំ និងវិធានការ**

❖ **វិធានការរបស់ ឯកឧត្តម កើត សុធា អភិបាលខេត្តប៉ៃលិន**

- បន្តពង្រឹងសមត្ថភាពគណៈបញ្ជាការឯកភាព អាជ្ញាធរ និងសមត្ថកិច្ចនៅតាមខ្សែបន្ទាត់ព្រំដែន ។

- សិក្សាឡើងវិញអំពីតំបន់នៃការឆ្លងកាត់របស់ប្រជាពលរដ្ឋទាំងពីរ ថាកន្លែងណាត្រូវរឹតបន្តឹង កន្លែងណាត្រូវសម្រួល និងកន្លែងណាត្រូវបិទ ដើម្បីបង្កើតនូវការគ្រប់គ្រងមួយដែលមានប្រសិទ្ធិភាព ។
- សហការជាមួយអាជ្ញាធរខេត្តជាប់ព្រំដែន ដើម្បីសម្របសម្រួល គ្រប់គ្រងឲ្យបាននូវព័ត៌មាន និងទិន្នន័យពលករជាប្រចាំថ្ងៃ ។
- ចំពោះការកសាងមណ្ឌលសំចត បើមានទីតាំង គួរចាប់ដំណើរការបណ្តើរៗ ។

❖ **វិធានការរបស់ ឯកឧត្តម ច័ន្ទ សុផល អភិបាលខេត្តបាត់ដំបង**

- ត្រូវចូលទៅសហការជាមួយអាជ្ញាធរថៃឲ្យបានជិតដល់ ដើម្បីដឹងថាពលករខ្មែរទៅធ្វើការនៅទីនោះមានចំនួនប៉ុន្មាន ធ្វើអ្វីខ្លះ នៅកន្លែងណាខ្លះ ។
- បន្តចុះសិក្សា និងពិនិត្យតាមដានស្ថានភាពពលករឆ្លងកាត់ព្រំដែនជាប្រចាំ ព្រមទាំងសហការគ្នាឲ្យបានល្អប្រសើរក្នុងការសម្របសម្រួលជួយពលករ និងធ្វើការទិន្នន័យឲ្យបានច្បាស់លាស់ ។
- គាំទ្រក្នុងការរកទីតាំងសម្រាប់ធ្វើសាងសង់មណ្ឌលសំចត ដែលនឹងអាចធ្វើឲ្យការគ្រប់គ្រងមានលក្ខណៈល្អប្រសើរ ទោះរាងស្មុគ្រស្មាញបន្តិចតែយើងត្រូវតែពុះពារ ។

❖ **វិធានការរបស់ ឯកឧត្តម ស៊ួន បវរ អភិបាលខេត្តបន្ទាយមានជ័យ**

- ចង់ឲ្យមានការិយាល័យធ្វើលិខិតឆ្លងដែន វីសា និងប័ណ្ណការងារសម្រាប់ពលករនៅក្នុងក្រុងប៉ោយប៉ែតតែម្តង ដើម្បីពួកគាត់មានភាពងាយស្រួលទំនាក់ទំនងទាន់សភាពការណ៍ ។
- ខេត្តបន្ទាយមានជ័យមានច្រកទ្វារស្របច្បាប់ចំនួន០៣ ប៉ោយប៉ែត ម៉ាឡៃ និងបឹងទំពូន ហើយចង់ស្នើសុំបើកច្រកទ្វារចំនួន០២ទៀតគឺ ចំការគោ និងបឹងត្រកួន ។
- អាជ្ញាធរស្រុកជាប់ព្រំដែនត្រូវមានទំនាក់ទំនងល្អជាមួយថៃក្នុងការសម្របសម្រួលពលករ និងមានយន្តការឯកភាពគ្នាក្នុងការបញ្ជូនទៅមក ។
- អាជ្ញាធរស្រុកក្នុងខេត្តបន្ទាយមានជ័យទាំងអស់ត្រូវណែនាំដល់មេភូមិ ក្នុងការចាត់វិធានការគ្រប់គ្រងប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន ដោយស្រង់បញ្ជីឈ្មោះគ្រួសារដែលមានសមាជិកទៅថៃ ដើម្បីងាយស្រួលគ្រប់គ្រង ។
- ឯកភាពក្នុងការកសាងមណ្ឌលសំចតឲ្យបានឆាប់រហ័សទៅតាមលទ្ធភាព កាន់តែឆាប់ចាប់ផ្តើមកាន់តែល្អប្រសើរ ។

❖ **ប្រសាសន៍ណែនាំ និងវិធានការរបស់ លោកជំទាវ ងួ ម៉ឺនអេង**

- **សម្តេចក្រឡាហោម** បានផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ ឲ្យពង្រឹងរបៀបរបបគ្រប់គ្រងពលករឡើងវិញ និងជម្រុញការពិនិត្យសិក្សាឲ្យបានឆាប់រហ័សនូវសកម្មភាពប្រែប្រួលថ្មីនេះ ដើម្បីមានវិធានការដោះស្រាយ និងគ្រប់គ្រងឲ្យបានសមស្រប និងឆាប់រហ័ស ហើយក្នុងការជួយសម្របសម្រួលពលករនេះគឺមិនត្រូវដាក់បន្ទុក ឬបន្ទោសពួកគាត់នោះទេ គឺមានតែសម្របសម្រួលជួយពួកគាត់ឲ្យអស់ពីលទ្ធភាពឲ្យពួកគាត់បានទៅដល់លំនៅដ្ឋានដោយសុខសុវត្ថិភាព ។ ចំពោះការកសាងមណ្ឌលសំចត សម្តេចបានឲ្យក្រសួងសង្គមកិច្ចពិនិត្យលទ្ធភាពជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តែច្រកនីមួយៗត្រូវរកទីតាំងដោយខ្លួនឯង ។
- រាជរដ្ឋាភិបាលចង់ដឹងអំពីអ្វីដែលជាភាពថ្នាំងថ្នាក់របស់ប្រជាពលរដ្ឋ ដើម្បីមានវិធានការដោះស្រាយឲ្យបានសមស្រប និងមានប្រសិទ្ធិភាពខ្ពស់ ។

- គណៈឯកភាពខេត្តត្រូវសហការគ្នាក្នុងការផ្លាស់ប្តូរ និងគ្រប់គ្រងព័ត៌មានចេញចូល និងត្រូវមានអ្នកប្រមូលផ្តុំព័ត៌មានជាប្រចាំ (ត្រូវរាយការណ៍អ្វីដែលពិត កុំខ្លាចខុស ដើម្បីឲ្យថ្នាក់ដឹកនាំមានមូលដ្ឋានក្នុងការដោះស្រាយ) ។
- ត្រូវត្រៀមជាស្រេចក្នុងការទទួលពលករ និងសូមឲ្យអ្នកទទួលពលករត្រូវមានឥរិយាបថ និងសីលធម៌ល្អក្នុងការជួយសម្របសម្រួល ។
- មន្ទីរការងារត្រូវក្តាប់ឲ្យបាននូវក្រុមហ៊ុននាំពលករ ផ្តល់អាទិភាពដល់ពលករស្របច្បាប់ និងចាត់វិធានការចំពោះពលករខុសច្បាប់ និងត្រូវសហការជាមួយនគរបាលអន្តោប្រវេសន៍ឲ្យកាន់តែជិតស្និទ្ធ ។
- ចំពោះប្រជាពលរដ្ឋចេញទៅតាមរយៈក្រុមហ៊ុនក្នុងរយៈពេលខ្លី មួយអាទិត្យ ឬកន្លះខែ ក្រុមហ៊ុនត្រូវតែមកទំនាក់ទំនងអាជ្ញាធរ និងសមត្ថកិច្ច ព្រមទាំងបញ្ជាក់ថ្ងៃចេញនិងថ្ងៃមកវិញ ដើម្បីឲ្យមានការត្រួតពិនិត្យតាមដាន និងគ្រប់គ្រងបានច្បាស់លាស់ និងមានលក្ខណៈជាប្រព័ន្ធ ។
- គាំទ្រក្នុងការចូលទៅសហការជាមួយអាជ្ញាធរថៃ និងសួរសុខទុក្ខពលករឲ្យបានជិតដល់ ដើម្បីឲ្យបានដឹងពីអ្វីដែលជាភាពថ្នាំងថ្នាក់របស់ប្រជាពលរដ្ឋ ដើម្បីមានវិធានការដោះស្រាយឲ្យបានសមស្រប និងមានប្រសិទ្ធិភាពខ្ពស់ ។
- ឯកភាពចំពោះការសាងសងមណ្ឌលសំចត ត្រូវត្រៀមទីតាំង និងសង់បណ្តើរៗខ្លួនឯង កុំរង់ចាំជំនួយ ។ សូមឲ្យអាជ្ញាធរខេត្តសហការជាមួយក្រសួងសង្គមកិច្ច និងគ.ជ.ប.ជ ដើម្បីពិនិត្យមើលលទ្ធភាព និងលើកជាគម្រោង ព្រមទាំងរៀបចំយន្តការ និងត្រៀមលក្ខណៈផ្តល់សេវា ។ មណ្ឌលសំណាតដែលនឹងត្រូវសាងសង់នេះអាចនឹងក្លាយជាច្រកចេញចូលតែមួយនៅថ្ងៃពេលមុខ ដែលអាចឲ្យពលករទាំងអស់មកទំនាក់ទំនងសួរនាំព័ត៌មាន និងដោះស្រាយបញ្ហា ។
- ចំពោះច្រករបៀង បើបិទមិនជាប់ ត្រូវសម្របសម្រួលឲ្យចេញទៅដោយស្របច្បាប់ និងធ្វើការគ្រប់គ្រងឲ្យបានច្បាស់លាស់ តែច្រកចេញទៅកាប់ឈើត្រូវបិទឲ្យជិត ។
- គាំទ្រចំពោះវិធានការគ្រប់គ្រងប្រជាពលរដ្ឋតាមបណ្តាយព្រំដែនឆ្លងទៅធ្វើការងារប្រចាំថ្ងៃ តាមរយៈការធ្វើបញ្ជីឈ្មោះប្រជាពលរដ្ឋដែលត្រូវចេញទៅ ឬគ្រួសារដែលមានសមាជិកទៅថៃ ហើយពេលចេញទៅត្រូវប្រគល់បញ្ជីឈ្មោះទៅនគរបាលច្រក ដើម្បីពិនិត្យផ្ទៀងផ្ទាត់ចំនួនចេញនិងចូលឲ្យបានច្បាស់លាស់។
- ចង់ឲ្យមានការប្រមូលផ្តុំអាជីវករខ្មែរលក់ដូរនៅក្នុងផ្សារព្រំដែនថៃ មកធ្វើការសាកសួរ ណែនាំ និងប្រាប់អំពីគោលនយោបាយពាក់ព័ន្ធ ។
- ប្រទេសថៃអនុវត្តវិធានការគ្រប់គ្រងពលករបរទេសលើកនេះ គឺចង់រក្សាចំណាត់ថ្នាក់នៃការវាយតម្លៃការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់ខ្លួនមិនឲ្យធ្លាក់ចុះ ដោយការចាប់បញ្ជូនពលករចេញនេះមានអង្គការសង្គមស៊ីវិលអន្តរជាតិជាអ្នកពិនិត្យតាមដាន ព្រមជាមួយគ្នានោះថៃក៏បានដាក់បន្ទុកនេះមកលើប្រទេសបញ្ជូនផងដែរ ។

## ខ. សន្និដ្ឋាន

យោងទៅតាមការចុះសិក្សា និងពិនិត្យតាមដានរួចមក យើងសង្កេតឃើញថាស្ថានភាពនៃការចាប់បញ្ជូនលើកនេះមិនមានស្ថានភាពអាក្រក់ ឬលំបាកដូចជាការចាប់បញ្ជូនមកយ៉ាងគំហុកកាលពីឆ្នាំ២០១៤ឡើយ ហើយស្ថានភាពនៃការចាប់បញ្ជូនមកគឺមានចំនួនច្រើនតែនៅច្រកទ្វារអន្តរជាតិប៉ោយប៉ែត និងមានចំនួនមធ្យមនៅច្រកទ្វារអន្តរជាតិដូង ដោយសារច្រកដូងនេះមានទីតាំងធំទូលាយស្រួលគ្រប់គ្រង ចំណែកនៅច្រកទ្វារអន្តរជាតិព្រំគីមិនមានការបញ្ជូនពលករមកទេ តែក៏មានពលករមួយចំនួនទៀតបានរត់ចេញមកតាមច្រករបៀងផងដែរ តែទោះ

យ៉ាងណាយើងសង្កេតឃើញថា ពលករដែលបានចាប់បញ្ជូនមកភាគច្រើនមានស្ថានភាព និងទឹកមុខស្រស់ធម្មតា មិនមានអ្វីជាទុក្ខកង្វល់ឡើយ ហើយមានបំណងធ្វើឯកសារស្របច្បាប់ដើម្បីត្រឡប់ទៅធ្វើការនៅប្រទេសថៃវិញផងដែរ ជាពិសេសគឺពួកគាត់មានការយល់ដឹងអំពីច្បាប់ទម្លាប់ផ្សេងៗច្រើនជាងមុន ។ បើពិនិត្យមើលឲ្យបានស៊ីជម្រៅយើងសង្កេតឃើញថា ការអនុវត្តវិធានការចាប់បញ្ជូនមកលើកនេះគឺថៃគ្រាន់តែចង់បង្ហាញសង្គមស៊ីវិលអន្តរជាតិឲ្យមើលឃើញថាខ្លួនក៏បានខិតខំយកចិត្តទុកដាក់ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគ្រប់គ្រងពលករបរទេសដែរ ដើម្បីរក្សាចំណាត់ថ្នាក់របស់ខ្លួនមិនឲ្យធ្លាក់ចុះ ហើយក៏ឆ្លៀតឱកាសដាក់បន្ទុកមកលើប្រទេសបញ្ជូន មិនតែប៉ុណ្ណោះក៏បានកេងចំណេញផងដែរតាមរយៈការរៀបចំធ្វើបែបបទឯកសារថ្មីស្របច្បាប់ដែលទាមទារឲ្យពលករធ្វើការចំណាយជាថ្មីម្តងទៀត ។ សរុបមក ទោះបីជាស្ថានការណ៍មិនលំបាកក្តីក៏អាជ្ញាធរមូលដ្ឋាន សមត្ថកិច្ច មន្ទីរ-អង្គភាពជំនាញ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធ បានសហការគ្នាបានយ៉ាងជិតស្និទក្នុងការប្រឈម និងត្រៀមជាស្រេចជាមួយស្ថានការណ៍ថ្មីនេះ ព្រមទាំងមានការសហការល្អជាមួយអាជ្ញាធរថៃជាប់ព្រំដែន ក្នុងការសម្របសម្រួលជួយពលករយើងឲ្យបានចាកចេញមក និងបញ្ជូនទៅដល់លំនៅដ្ឋានដោយសុខសុវត្ថិភាព ។ មិនតែប៉ុណ្ណោះយើងក៏ត្រូវស្វែងរកវិធានការជាបន្តទៀត ដើម្បីត្រៀមប្រឈម និងគ្រប់គ្រងឲ្យបាននូវស្ថានការថ្មីផ្សេងៗទៀតដែលអាចនឹងកើតឡើងនៅពេលខាងមុខ ហើយអ្វីដែលពលករត្រូវការជាចម្បងនិងរាជរដ្ឋាភិបាលកំពុងតែចាប់ផ្តើមដំណើរការជាចាំបាច់នោះគឺ មណ្ឌលសំចតនៅតាមច្រកទ្វារនីមួយៗសម្រាប់ទទួលពលករ ដែលនៅថ្ងៃមុខមណ្ឌលទាំងនេះនឹងក្លាយទៅជាច្រកចេញចូលតែមួយ សម្រាប់ផ្តល់ព័ត៌មាន និងសេវាដល់ពលករទេសន្តរប្រវេសន៍ ។ ជាចុងក្រោយ ប្រជាពលរដ្ឋដែលរស់នៅតាមណ្តោយខ្សែបន្ទាត់ព្រំដែនក៏បានសំណូមពរផងដែរក្នុងការបើកច្រកឡើងវិញឲ្យបានឆាប់ ដើម្បីពួកគាត់អាចចេញទៅធ្វើការប្រចាំថ្ងៃ ។

ភ្នំពេញ ថ្ងៃទី២៤ខែ កក្កដា ឆ្នាំ២០១៧
**អ្នកធ្វើរបាយការណ៍**

ចំ.ស្រី ហ៊ុ.សោភ:

បានឃើញ និង ឯកភាព
ភ្នំពេញ ថ្ងៃទី ២៤ ខែ ០៧ ឆ្នាំ២០១៧
**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជុំ-ម៉ុនអេង**